**Declassified to Public**
**12 April 2013**

D373/2

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០១០

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 03 / 06 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើសុំជាជម្រើសរបស់លោក អៀង សារី ស្ដីពីការកំណត់ព្រំដែនចំពោះការអនុវត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរនៅលើអនុសញ្ញាទីក្រុងហ្សឺណែវ នៅ អវតក**

---

ដាក់ដោយ៖

**សហមេធាវីរបស់លោក អៀង សារី**
លោក អាង ឧត្តម
លោក Michael G. KARNAVAS

ផ្ញើជូន៖

**សហចៅក្រមស៊ើបអង្កេត**
លោក យូ ប៊ុនឡេង
លោក Marcel LEMONDE

**សហព្រះរាជអាជ្ញា**
អ្នកស្រី ជា លាង
លោក Andrew CAYLEY

ក្រុមមេធាវីការពារក្ដីទាំងអស់

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 01 / 06 / 2010
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (ពីនេះតទៅហៅថា "មេធាវីការពារក្តី") តទៅនេះ សូមដាក់សំណើនេះ ស្តីពីការកម្រិតអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ[1] (ពីនេះតទៅហៅថា "អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ") បើសិនជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរនេះត្រូវយកមកអនុវត្តនៅ អ.វ.ត.ក នេះ[2]។ ការតតាំងបន្ថែមទៅលើបញ្ហាយុត្តាធិការគួរត្រូវបានអនុញ្ញាត ដោយហេតុថា៖ ១)អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរត្រូវបានកម្រិតត្រឹមតែ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ២)អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរអាចអនុវត្តបានតែក្នុងពេលមានជម្លោះប្រដាប់អាវុធអន្តរជាតិតែប៉ុណ្ណោះ ៣)ត្រូវតែមានចំណងទាក់ទងរវាងអំពើដែលមានចែងក្នុងច្បាប់ទៅនិងជម្លោះប្រដាប់អាវុធអន្តរជាតិ ៤)ជនរងគ្រោះ ឬ សម្ភារៈដែលរងនូវអំពើដែលមានចែងក្នុងច្បាប់នេះ ត្រូវតែមានលក្ខណសម្បត្តិជាមនុស្ស ឬ ទ្រព្យសម្បត្តិដែលទទួលការការពារ អនុលោមទៅតាមអនុសញ្ញាទីក្រុងហ្សឺណែវ និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ៥)កត្តាអត្តនោម័តដែលតម្រូវចំពោះបទល្មើសបំពារបំពានយ៉ាងធ្ងន់ធ្ងរគឺ ចេតនា ឬ នៅក្នុងកាលៈទេសៈជាក់លាក់គឺ ការព្រហើន (recklessness) ៦)មានតែទម្រង់នៃទំនួលខុសត្រូវ ដូចជាការប្រព្រឹត្ត និង ការបញ្ជា ប៉ុណ្ណោះ ដែលអាចអនុវត្តបានចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ និង ៧)និយមន័យនៃអំពើខ្លះក្នុងចំណោមអំពើដែលមានចែងក្នុងច្បាប់នេះត្រូវតែមានដែនកម្រិត ដូចជាការធ្វើទារុណកម្ម ការបំផ្លិចបំផ្លាញ និង ការធ្វើឱ្យខូចខាតធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិ ដែលមិនមានយុត្តិកម្មតាមភាពចាំបាច់នៃការប្រើកម្លាំងយោធា និងត្រូវបានប្រព្រឹត្តដោយខុសច្បាប់និងយ៉ាងព្រៃផ្សៃ និង ការចាប់ជនស៊ីវិលធ្វើជាចំណាប់ខ្មាំង។ ឧបសម្ព័ន្ធមានភ្ជាប់មកជាមួយ[3]។

---

[1] អនុសញ្ញាទី (I) សម្រាប់ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពរបស់អ្នកជំងឺ និង អ្នករងរបួសនៅក្នុងជួរកងកម្លាំងប្រដាប់អាវុធក្នុងសមរភូមិ, ទីក្រុងហ្សឺណែវ, ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ (ពីនេះតទៅហៅថា "អនុសញ្ញាទី I")។ អនុសញ្ញាទី (II) សម្រាប់ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពរបស់អ្នកជំងឺ និង អ្នករងរបួស និង សមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលលិចកប៉ាល់នៅតាមសមុទ្រ, ទីក្រុងហ្សឺណែវ, ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ (ពីនេះតទៅហៅថា "អនុសញ្ញាទី II")។ អនុសញ្ញាទី (III) ទាក់ទងនឹងការប្រព្រឹត្តទៅលើឈ្លើយសឹក, ទីក្រុងហ្សឺណែវ, ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ (ពីនេះតទៅហៅថា "អនុសញ្ញាទី III")។ អនុសញ្ញាទី (IV) ទាក់ទងនឹងការការពារជនស៊ីវិលនៅក្នុងអំឡុងពេលនៃសង្គ្រាម, ទីក្រុងហ្សឺណែវ, ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ("អនុសញ្ញា IV")។ (ទាំងអស់នេះហៅថា "អនុសញ្ញាទីក្រុងហ្សឺណែវ")។

[2] *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើសុំរបស់ អៀង សារី ជំទាស់ទៅនឹងការអនុវត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ នៅ អវតក ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០ ឯកសារលេខ D379 ERN: 00511576-00511589 (ពីនេះតទៅហៅថា "សំណើសុំទីមួយស្តីពីអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ")។

[3] *សូមមើល* ឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ចែងអំពីច្បាប់ដែលពាក់ព័ន្ធនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរនានាដែលសរសេរចងក្រងជាច្បាប់បញ្ចូលក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") និង តុលាការឧក្រិដ្ឋកម្មអន្តរជាតិ

00526295



## I. ការទទួលយកបណ្តឹងជំទាស់នឹងយុត្តាធិការនេះ

១. បញ្ហាយុត្តាធិការត្រូវតែលើកយកមកពិភាក្សានៅក្នុងដំណាក់កាលនេះនៃដំណើរការនីតិវិធី។ តាមរយៈបណ្តឹងជំទាស់នឹងយុត្តាធិការ មេធាវីការពារក្តីមិនស្នើឲ្យ កសចស ធ្វើបុរេវិនិច្ឆ័យទៅលើអង្គហេតុនៅមុនដីកាដំណោះស្រាយនោះទេ។ មេធាវីការពារក្តី ស្នើសុំត្រឹមតែថា កសចស កំណត់ពីដែនកម្រិត នៃការអនុវត្តចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ បើសិនជា កសចស សម្រេចថា អវតក មានយុត្តាធិការក្នុងការចោទប្រកាន់លោក អៀង សារី ពីបទអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ។ មេធាវីការពារក្តី មានសិទ្ធិទទួលបានការជូនដំណឹងអំពី ការកំណត់ព្រំដែនចំពោះបទល្មើសនានា ដែល អវតក មានយុត្តាធិការ ដើម្បីកាត់សេចក្តីលោក អៀង សារី និងដើម្បីលើកឡើងអំពីការជំទាស់តវ៉ានឹងបញ្ហាយុត្តាធិការដែលមានលក្ខណៈស្របច្បាប់[4]។

២. អង្គបុរេជំនុំជម្រះ បានយល់ឃើញថា ទាំងបទដ្ឋានអន្តរជាតិ និងមាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក តម្រូវអោយមានចែងច្បាស់លាស់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[5]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនអាចមានចែងច្បាស់លាស់ឡើយ លុះត្រាតែមានការរៀបរាប់អំពីការកំណត់ព្រំដែនចំពោះបទល្មើសនានា ដែលមានសំអាងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ជាការពិត នៅក្នុងសាលដីកាអំពី JCE ទាំងមូល អង្គបុរេជំនុំជម្រះ បានកំណត់ព្រំដែនចំពោះការអនុវត្តនូវទម្រង់នៃការទទួលខុសត្រូវ JCE ។

៣. ដោយទទួលស្គាល់ថា នៅតុលាការ *បណ្តោះអាសន្ន(ad hoc)* នានា ការជំទាស់តវ៉ាទាក់ទងទៅនឹងចរិតលក្ខណៈទូទៅមួយចំនួននៃបទល្មើស គឺជាចំណោទដែលនឹងត្រូវដោះស្រាយនាពេលជំនុំជម្រះ[6] អវតក ត្រូវតែមានលក្ខណៈខុសប្លែកពីតុលាការ *បណ្តោះអាសន្ន*ទាំងនោះនៅក្នុងទិដ្ឋភាពមួយចំនួន។ ការកំណត់ព្រំដែនចំពោះបទល្មើស គឺជាចំណុចមួយនៃទិដ្ឋភាពទាំងនេះ។ ការកំណត់ព្រំដែនចំពោះ

---

សម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") និង របៀបដែលវាត្រូវបានគេយកទៅអនុវត្តតាមរយៈយុត្តាធិការនៅតុលាការ ICTY។

[4] មេធាវីការពារក្តី មិនអាចសន្និតថា អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ អាចអនុវត្តបាននៅ អវតក ដោយគ្រាន់តែដោយសារអំពើនេះត្រូវបានយកមកអនុវត្តក្នុងសំណុំរឿង ០០១ នោះទេ។

[5] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ៣៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម JCE ចុះថ្ងៃទី ២០ ឧសភា ២០១០ ("សាលដីកាអំពី JCE") ឯកសារលេខ D97/14/15, ERN: 00486521-00486589 កថាខណ្ឌ ៣៤។

[6] *ដូចលេខយោងខាងលើ* កថាខណ្ឌ ២៣-២៤។

បទល្មើសត្រូវតែដោះស្រាយនៅមុនពេលចេញដីកាដំណោះស្រាយ ដើម្បីទុកពេលអោយមេធាវីការពារក្តីមានពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំធ្វើការជំទាស់តវ៉ានានា នៅមុនពេលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះប្រឆាំងនឹងលោក អៀង សារី។ ដោយទទួលស្គាល់ថា វិធាន ៧៤(៣) អាចចែងមិនច្បាស់លាស់ អំពីសិទ្ធិរបស់មេធាវីការពារក្តីក្នុងប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ គេអាចធ្វើការអះអាងថា ដោយបង្កប់ន័យថាគ្មានអ្វីហាមឃាត់មេធាវីការពារក្តីមិនអោយធ្វើដូច្នេះនោះ ជាពិសេសដើម្បីជាប្រយោជន៍នៃយុត្តិធម៌ និងដើម្បីរក្សាអោយមានសមភាពនៃមធ្យោបាយតទល់ក្តី (equality of arms)។ នៅក្នុងករណីនេះ បើសិនជាបទល្មើសមិនត្រូវបានកំណត់ព្រំដែននៅមុនពេលការចេញដីកាដំណោះស្រាយ វាអាចជាការចាំបាច់សម្រាប់មេធាវីការពារក្តីក្នុងការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយតាមវិធាន ៧៤(៣)(ក)[7]។

៤. ករណីនេះនឹងទៅជារឿងមិនវាងវៃសម្រាប់ កសចស ក្នុងការរារាំងមិនអោយមានការកំណត់ព្រំដែនចំពោះចរិតលក្ខណៈទូទៅនៃអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ រហូតដល់មានដីកាដំណោះស្រាយនោះ បើសិនជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ត្រូវយកមកអនុវត្តនៅ អវតក។ រឿងបែបនេះបានត្រឹមតែអូសបន្លាយពេលប្តឹងឧទ្ធរណ៍នឹងបញ្ហាយុត្តាធិការ ហើយជាការខ្ជះខ្ជាយធនធានតុលាការផង។ ករណីក៏អូសបន្លាយពេលបន្ថែមទៀត សម្រាប់ដំណើរការនីតិវិធីប្រឆាំងនឹងលោក អៀង សារី ដែល កសចស មានបំណងចង់ជៀសវាងនោះ[8]។ សំខាន់ជាងនេះទៅទៀត ការអូសបន្លាយពេលក្នុងការកំណត់ព្រំដែនចំពោះចរិតលក្ខណៈទូទៅនៃអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ លុះត្រាដល់ពេលមានដីកាដំណោះស្រាយ បង្កអោយមានការរាំងស្ទះជាខ្លាំងដល់លទ្ធភាពរបស់មេធាវីការពារក្តីក្នុងការត្រៀមរៀបចំនូវការការពារក្តីអោយបានពេញលេញសម្រាប់លោក អៀង សារី។ គេអាចប្រមើលឃើញមាននូវបញ្ហាអង្គច្បាប់មានចំនួនច្រើនមែនទែន ភ្លាមៗបន្ទាប់ពីមានដីកាដំណោះស្រាយ ខណៈពេលដែលឱកាសអំណោយផលមានរយៈពេលតែ ៣០ថ្ងៃ ដែលផ្តល់ឲ្យដោយវិធាន ៧៥ ដើម្បីប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចនានារបស់ កសចស។ ជាបច្ច័យ ការអូសបន្លាយពេលក្នុងការកំណត់ព្រំដែនចំពោះចរិតលក្ខណៈទូទៅនៃអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ផ្តល់ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តី ដោយយុត្តិធម៌។

---

[7] វិធាន ៧៤(៣)(ក) អោយសិទ្ធិដល់មេធាវីការពារក្តីដើម្បីប្តឹងឧទ្ធរណ៍អះអាងអំពីយុត្តាធិការរបស់ អវតក ទៅអង្គបុរេជំនុំជម្រះ។

[8] សូមមើលជាឧទាហរណ៍ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចធ្វើការព្រមានតាមវិធាន ៣៨ ចុះថ្ងៃទី ២៥ កុម្ភៈ ២០១០ ឯកសារលេខ D367, ERN: 00478513-00478519 កថាខណ្ឌ ១៣។

៥. ការកំណត់ព្រំដែននៃបទល្មើស ដូចនជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ គឺដើម្បីអោយគេផ្តល់ការជូនដំនឹងអោយបានគ្រប់គ្រាន់ ដែលជាបន្តបន្ទាប់គឺមានភាពងាយស្រួលសម្រាប់ការបំពេញការស៊ើបសួរតាមវិធាន ៥៥(១០)[9]។ កសចស បានពិចារណាអំពីពាក្យសុំនានាកាលពីកន្លងទៅតាមវិធាន ៥៥(១០) ដើម្បីផ្តល់ការជូនដំណឹងអោយបានគ្រប់គ្រាន់[10]។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះក៏បានកំណត់ព្រំដែនផងដែរចំពោះការយកមកអនុវត្តនូវបទល្មើសនានានៅ អវតក[11] ។ កសចស ត្រូវតែយកលំនាំទៅតាមនេះដែរ ដើម្បីកំណត់ព្រំដែនចំពោះគ្រប់បទល្មើសទាំងអស់ដែលអាចយកមកអនុវត្តនៅ អវតក ។

៦. កាលពីពេលកន្លងទៅ នៅពេលដែលមេធាវីការពារក្តីបានព្យាយាមប្តឹងជំទាស់ទៅនឹងយុត្តាធិការ[12] ក.ស.ច.ស បានបដិសេធចោលបណ្តឹងទាំងនោះដោយអះអាងថា មេធាវីការពារក្តីបានព្យាយាមស្នើសុំអោយបកស្រាយច្បាប់ ហើយថា កង្វល់អំពីការជូនដំណឹងដោយបានត្រឹមត្រូវគ្រប់គ្រាន់ដល់ជនត្រូវចោទ មិនចោទជាបញ្ហាទេពាក់ព័ន្ធនឹងបញ្ហានានាដូចជា អំពើប្រល័យពូជសាសន៍ ឬ ការទទួលខុសត្រូវរបស់ថ្នាក់លើឡើយ ដោយហេតុថា បញ្ហាទាំងនេះត្រូវបានចែងរួចមកហើយនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[13]។ អង្គបុរេជំនុំជម្រះបានយល់ឃើញថា ទម្រង់ និងអង្គច្បាប់នៃការ

---

[9] សូមកត់សំគាល់ថា មិនដូចភាសាអង់គ្លេសនៃវិធានផ្ទៃក្នុង ភាសាបារាំងបានចែងត្រឹមតែថាសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរត្រូវតែមាន "មានប្រយោជន៍"។ រឿងក្តី អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចស្តីពីការអនុវត្តនូវ អវតក នូវទម្រង់នៃការទទួលខុសត្រូវដែលគេហៅថា សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៨ ធ្នូ ២០០៩ ឯកសារលេខ D97/13, ERN: 00411047-00411056 លេខយោងជើងទំព័រ ២៣។

[10] *ដូចលេខយោងខាងលើ* កថាខណ្ឌ ៨ ។

[11] *សូមមើល* សាលដីកាអំពី JCE ។

[12] *សូមមើល ឧទាហរណ៍ រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សំណើលោក អៀង សារី ប្រឆាំងនឹងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើនៅ អ.វ.ត.ក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារលេខ D345/2, ERN: 00475513-00475527។ *រឿងក្តី អៀង សារី* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សំណើរបស់លោក អៀង សារី ប្រឆាំងទៅនឹងលទ្ធផលនៃការយកច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០០៩ ឯកសារលេខ D240, ERN: 00401925-00401940។

[13] *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រដែលបានកំណត់ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារលេខ D345/1, ERN: 00452734-00452736 កថាខណ្ឌ៤។ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទៅលើលទ្ធផលនៃការយកច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មកអនុវត្តនៅ អ.វ.ត.ក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០០៩ ឯកសារលេខ D240/3, ERN: 00421137-00421140 ("ដីកាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍") កថាខណ្ឌ៣។

00526298



ជំទាស់តវ៉ានឹងបញ្ហាយុត្តាធិការ[14]។

## III. ឧត្តិករណ៍

### ក. ការបំពារបំពានយ៉ាងធ្ងន់ធ្ងរត្រូវបានកំហិតត្រឹមការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ

៧. មាត្រា៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បញ្ជាក់ច្បាស់ថា អ.វ.ត.ក មានយុត្តាធិការទៅលើ "អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ១៩៤៩"[15]។ អ.វ.ត.ក គឺជាតុលាការកម្ពុជាផ្អែកលើប្រព័ន្ធ Civil Law ជាមូលដ្ឋាន៖ មានតែបទឧក្រិដ្ឋកម្មដែលមានចែងក្នុងច្បាប់ប៉ុណ្ណោះដែលត្រូវទទួលផ្តន្ទាទោស[16]។ អំពើរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ មានចែងយ៉ាងជាក់លាក់នៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រីឯអំពើរំលោភយ៉ាងធ្ងន់ធ្ងរទៅលើពិធីសារបន្ថែមទី១[17] គឺមិនមានចែងក្នុងច្បាប់នោះទេ។

៨. ពិធីសារបន្ថែមទី១ ទើបតែត្រូវបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជានៅថ្ងៃទី១៤ ខែមករា ឆ្នាំ ១៩៩៨[18]។ យុត្តាធិការទៅលើពេលវេលារបស់ អ.វ.ត.ក គឺគ្របដណ្តប់តែទៅលើអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ តែប៉ុណ្ណោះ។ ពិធីសារបន្ថែមទី១ មិនមែនជាអនុសញ្ញាដែលប្រទេសកម្ពុជាបានចុះហត្ថលេខា ឬ ផ្តល់សច្ចាប័នក្នុងអំឡុងពេលដែល អ.វ.ត.ក មានយុត្តាធិការទៅលើឡើយ។ អាស្រ័យហេតុនេះ ការអនុវត្តបញ្ញត្តិស្តីពីអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរនៅក្នុងពិធីសារបន្ថែមទី១ នឹងរំលោភទៅដល់ *គោលការណ៍គ្មានបទល្មើស ប្រសិនបើគ្មានច្បាប់*

---

[14] សាលដីកាអំពី JCE កថាខណ្ឌ ១៨ ។

[15] គូសបញ្ជាក់បន្ថែម។

[16] មាត្រា៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ចែងថា "ច្បាប់ព្រហ្មទណ្ឌ គ្មានអានុភាពជាប្រតិសកម្មទេ គឺថា បទល្មើសណាបានប្រព្រឹត្តមុនបទបញ្ញត្តិរបស់ច្បាប់ បទល្មើសនុះមិនអាចត្រូវនិគ្រោះដោយទោសរបស់ច្បាប់ដែលទើបនឹងបញ្ញត្តិថ្មីនេះបានទេ"។

[17] ពិធីសារបន្ថែមទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និង ទាក់ទងទៅនឹងការពារជនរងគ្រោះនៃជម្លោះប្រដាប់អាវុធអន្តរជាតិ (ពិធីសារទី I) ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧ មាត្រា៨៥។

[18] ប្រទេសហត្ថលេខី និង បានផ្តល់សច្ចាប័នដល់ពិធីសារបន្ថែមទី I *អាចរកមើលបាននៅគេហទំព័រ៖* http://www.icrc.org/ihl.nsf/WebSign?ReadForm&id=470&ps=P។

*ថែង (nullum crimen sine lege)*[19] កិច្ចព្រមព្រៀង[20] និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[21] មិនខាន ។

៩. ពិធីសារបន្ថែមទី១ មិនអាចត្រូវបានចាត់ទុកថាជាក្រមដែលពេលនោះគេហៅថា ទម្លាប់អន្តរជាតិបានទេ[22]។ នៅចុងឆ្នាំ១៩៧៨ នៅពេលដែលមានរដ្ឋចំនួន៥៤ បានចុះហត្ថលេខាទៅលើ ពិធីសារបន្ថែមទី១ នេះ[23] មានត្រឹមតែ៣រដ្ឋប៉ុណ្ណោះដែលបានផ្តល់សច្ចាប័ន រួមមាន៖ ប្រទេសអែលសាលវ៉ាឌ័រ ប្រទេសហ្គាណា និង ប្រទេសលីប៊ី។ រដ្ឋភាគច្រើនមិនបានផ្តល់សច្ចាប័នដល់ ពិធីសារបន្ថែមទី១នេះទេ រហូតពេលក្រោយពីនោះមក[24]។ ប្រការគួរឱ្យកត់សម្គាល់នោះគឺថា ក្នុងចំណោម

---

[19] គោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង (nullum crimen sine lege)* ត្រូវបានទទួលស្គាល់ដោយមាត្រា១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ("ICCPR") ដែលត្រូវតែទទួលការគោរពនៅ អ.វ.ត.ក អនុលោមតាមមាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា និង មាត្រា១៣(១) នៃកិច្ចព្រមព្រៀង។

[20] កិច្ចព្រមព្រៀង មាត្រា១ ចែងថា៖ "គោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និង ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និង ទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ០៦ មករា ១៩៧៩" (គូសបញ្ជាក់បន្ថែម)។

[21] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា១ ចែងថា៖ "ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និង ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅច្បាប់មនុស្សធម៌និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩" (គូសបញ្ជាក់បន្ថែម)។

[22] "ច្បាប់ទម្លាប់ចាប់ផ្តើមពីការអនុវត្តតន៍ជាទម្លាប់ ហើយបន្ទាប់មកប្រែក្លាយជាវិធានដែលចងកាតព្វកិច្ច នៅពេលដែលអ្នកអនុវត្តតាមវិធាននោះចាប់ផ្តើមចាត់ទុកការអនុវត្តនោះថាមានកាតព្វកិច្ចចំពោះពួកគេ"។ George P. Fletcher & Jens Ohlin, *ការទាមទារជាថ្មីនូវគោលការណ៍មូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌក្នុងករណីដារហ្វួរ (Reclaiming Fundamental Principles of Criminal Law in Darfur Case)*, 3 Int'l Crim. Just. 556 (ឆ្នាំ២០០៥)។ គេត្រូវកត់សម្គាល់ថា "វាមានការលំបាកក្នុងការបង្កើតឱ្យបាននូវមតិជាឯកច្ឆ័ន្ទគ្រប់គ្រាន់ ក្នុងការធ្វើឱ្យវិធានមួយក្លាយជាទម្លាប់អន្តរជាតិបាន"។ *ដូចជើងទំព័រខាងលើ*។

[23] *សូមមើល* បញ្ជីរដ្ឋជាភាគីរបស់ ICRC *អាចរកមើលបាននៅគេហទំព័រ៖* http://www.icrc.org/ihl.nsf/WebSign?ReadForm&id=470&ps=P។

[24] ការពិនិត្យទៅលើកាលបរិច្ឆេទនៃការចូលជាសមាជិក ឬ ការផ្តល់សច្ចាប័ន បានបង្ហាញថា រដ្ឋភាគច្រើនផ្តល់សច្ចាប័នដល់ពិធីសារបន្ថែមទី I រវាងឆ្នាំ១៩៨៥-៩៥។ រវាងឆ្នាំ១៩៨៥-៩០ មានការចូលជាសមាជិក/ការផ្តល់សច្ចាប័នថ្មីចំនួន៤៥ និង រវាងឆ្នាំ១៩៩០-៩៥ មានការចូលជាសមាជិក/ការផ្តល់សច្ចាប័នថ្មីចំនួន៤៤។ *សូមមើល* បញ្ជីរដ្ឋជាភាគី *អាចរកបាននៅគេហទំព័រ៖* http://www.icrc.org/ihl.nsf/WebSign?ReadForm&id=470&ps=P។

សមាជិកអចិន្ត្រៃយ៍ទាំងប្រាំនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ប្រទេសរុស្ស៊ីបានផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៨៩ ចក្រភពអង់គ្លេសក្នុងឆ្នាំ១៩៩៨ និង ប្រទេសបារាំងក្នុងឆ្នាំ២០០១[25] រីឯប្រទេសចិន និង សហរដ្ឋអាមេរិកមិនទាន់បានផ្តល់សច្ចាប័ននៅឡើយទេ[26]។ ប្រការនេះមិនបានបង្ហាញពីការអនុវត្តរបស់រដ្ឋដែលមានលក្ខណៈទូទៅ ស៊ីសង្វាក់គ្នា ដែលជាប្រការចាំបាច់ក្នុងការបង្កើតជាទម្លាប់អន្តរជាតិឡើយ។ "មានហេតុផលនាំឱ្យសង្ស័យចំពោះការសន្យាដែលមិនបានយកទៅអនុវត្តឱ្យបានពេញលេញ។ វិធានដែលចែងនោះមានភាពទទេស្អាត ពីព្រោះវាមានលក្ខណៈទូទៅពេក ហើយអាក្រក់ជាងនេះទៀត សេចក្តីថ្លែងនោះមានលក្ខណៈវៀចវេរ"[27]។ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើពិធីសារបន្ថែមទី១ ពិតជា មិនអាចយកមកអនុវត្តនៅ អ.វ.ត.ក តាមរយៈទម្លាប់អន្តរជាតិបានទេ។ ពិធីសារបន្ថែមទី១ មិនបានក្លាយជាច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងឆ្នាំ ១៩៧៥-៧៩ ឡើយ។

១០. ជាងនេះទៅទៀត មាត្រា២នៃលក្ខន្តិកៈតុលាការ ICTY មានលក្ខណៈដូចគ្នាបេះបិទទៅនឹងមាត្រា៦នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែរ ដោយអះអាងថា សាលាក្តី ឬ តុលាការនីមួយៗមានអំណាចចោទប្រកាន់ រៀបចំសវនាការ ចំពោះជន ឬ ជនជាប់ចោទគ្រប់រូបដែលបានប្រព្រឹត្ត ឬ បានបញ្ជាឱ្យប្រព្រឹត្ត "អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩"[28]។ តុលាការ ICTY៖ ១)មិនមានចែងក្នុងលក្ខន្តិកៈរបស់ខ្លួន ឬ យុត្តិសាស្ត្ររបស់ខ្លួន អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរដល់ពិធីសារបន្ថែមទី១ទេ និង ២)មិនមានចែងក្នុងលក្ខន្តិកៈរបស់ខ្លួន ឬ យុត្តិសាស្ត្ររបស់ខ្លួន អំពី អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរដល់ទម្លាប់អន្តរជាតិទេ ក្រៅពីអនុសញ្ញា

---

[25] *ដូចជើងទំព័រខាងលើ*។

[26] *ដូចជើងទំព័រខាងលើ*។

[27] Jens David Ohlin, *ការអនុវត្តទោសប្រហារជីវិតចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ (Applying the Death Penalty to Crimes of Genocide)*, Am. J. Int'l L. 747, 752 (ឆ្នាំ២០០៥)។ *សូមមើលផងដែរ* Fletcher & Ohlin ទំព័រ៥៥៧៖ "ប្រការអាចយល់បានគឺថា មេដឹកនាំបស្ចិមប្រទេសដែលទទួលការគោរព ... នឹងប្រកាស ... វិធានដាច់ខាតនៃ CIL។ ជាអកុសល ការគោរពដែលមានចំពោះពួកបស្ចិមប្រទេសមិនអាចត្រូវបានចាត់ទុកថាជាប្រភពនៃច្បាប់ទេ"។

[28] មាត្រា២ នៃលក្ខន្តិកៈតុលាការ ICTY ចែងជាផ្នែកថា៖ "តុលាការអន្តរជាតិមានអំណាចកាត់សេចក្តី ជនទាំងឡាយណាដែលបានប្រព្រឹត្ត ឬ បានបញ្ជាឱ្យប្រព្រឹត្តអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ លើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ..."។

ទីក្រុងហ្សឺណែវដែលផ្ទុះបញ្ហាំងនូវទម្លាប់អន្តរជាតិ[29]។ តាមការពិត ដូចអ្នកធ្វើអត្ថាធិប្បាយមួយរូបធ្វើការកត់សម្គាល់ថា៖ "មាត្រា២ នៃលក្ខន្តិកៈ [តុលាការ ICTY] ដើរតាមយ៉ាងជិតស្និទ្ធិទៅនឹងបទប្បញ្ញត្តិពាក់ព័ន្ធនានានៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ ដែលការយល់ដឹងបែបសេរី ... នឹងដើរហួសឆ្ងាយពីលក្ខខណ្ឌតម្រូវនៃមាត្រា២"[30]។ នៅពេលដែលលក្ខន្តិកៈតុលាការ ICTY និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មានលក្ខណៈដូចគ្នាបេះបិទយ៉ាងនេះ ជាពិសេសត្រង់បញ្ញត្តិដែលចែងអំពីយុត្តាធិការ ត្រឹមតែទៅលើ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ អ.វ.ត.ក គួរតែត្រូវបានត្រួសត្រាយដោយយុត្តិសាស្ត្ររបស់តុលាការ ICTY និង កំហិតអំពី អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើបទប្បញ្ញត្តិនានាដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ។

**ខ. អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរត្រឹមតែអាចអនុវត្តបាននៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ**

១១. មាត្រា២រួមនៃអនុសញ្ញាទីក្រុងហ្សឺណែវចែងដោយផ្នែកថា៖ "អនុសញ្ញានេះត្រូវអនុវត្តលើគ្រប់ករណីទាំងអស់នៃសង្គ្រាមដែលមានការប្រកាសត្រឹមត្រូវ ឬ គ្រប់ករណីមានជម្លោះប្រដាប់អាវុធផ្សេងទៀតដែលអាចកើតឡើងរវាងភាគីផ្តល់សច្ចាប័នពីរ ឬ ច្រើន ..."។ មានតែមាត្រា៣រួមនៃអនុសញ្ញាទីក្រុងហ្សឺណែវប៉ុណ្ណោះដែលអាចអនុវត្តបានចំពោះជម្លោះប្រដាប់អាវុធ ដែលមិនមានលក្ខណៈជាអន្តរជាតិ[31]។ ដោយហេតុថា អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរគឺជាផ្នែកមួយនៃអនុសញ្ញាក្រុងហ្សឺណែវ តែវាមិនស្ថិតក្រោមបញ្ញត្តិនៃមាត្រា៣រួម នៃអនុសញ្ញាទីក្រុងហ្សឺណែវទេនោះ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរត្រឹមតែអាចយកមកអនុវត្តបាន ចំពោះជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ។

១២. លក្ខន្តិកៈរបស់តុលាការ ICC កំណត់អំពី អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរថា ត្រឹមតែអាចយកមកអនុវត្តបានចំពោះជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ។ មាត្រា៨ចែងអំពីឧក្រិដ្ឋកម្មសង្គ្រាម

---

[29] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Tadić សំណុំរឿងលេខ *IT-94-1-T* សាលក្រម ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៧ ("សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Tadić*") កថាខណ្ឌ៥៧៧។

[30] Dieter Fleck, *ចំណុចខ្វះខាតនៃរបបនៃអំពើបំពារបំពារយ៉ាងធ្ងន់ធ្ងរ (Shortcomings of the Grave Breaches Regime),* 7(4) J. Int'l Crim. Just. 833, 840 (ឆ្នាំ២០០៩)។

[31] អនុសញ្ញាក្រុងហ្សឺណែវ មាត្រា៣រួម ចែងដោយផ្នែកថា៖ "ក្នុងករណីមានជម្លោះប្រដាប់អាវុធដែលមិនមានលក្ខណៈអន្តរជាតិកើតឡើងនៅក្នុងទឹកដីរបស់ភាគីដែលចុះហត្ថលេខាឬផ្តល់សច្ចាប័ន ភាគីជម្លោះនីមួយៗត្រូវជាប់កាតព្វកិច្ចអនុវត្ត តាមកម្រិតអប្បរមា នូវបទប្បញ្ញត្តិទាំងឡាយខាងក្រោមនេះ ..." (គូសបញ្ជាក់បន្ថែម)។

ដែលតុលាការ ICC មានយុត្តាធិការទៅលើ។ មាត្រា៨(២)(ក)ចែងអំពី <u>អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ</u>ដែលតុលាការ ICC មានយុត្តាធិការទៅលើ។ មាត្រា៨(២)(ខ)ចែងអំពីយុត្តាធិការរបស់តុលាការICC ទៅលើ "ការរំលោភធ្ងន់ធ្ងរទៅលើច្បាប់និងទម្លាប់ដែលមានជាធរមាននៅក្នុង<u>ជម្លោះប្រដាប់អាវុធអន្តរជាតិ</u>"[32]។ មាត្រា៨(២)(គ-ច)ចែងអំពីយុត្តាធិការរបស់តុលាការ ICTY ទៅលើឧក្រិដ្ឋកម្មសង្គ្រាមដែលនៅក្នុង "<u>ជម្លោះប្រដាប់អាវុធដែលមិនមានលក្ខណៈជាអន្តរជាតិ</u>"[33]។ អាស្រ័យហេតុនេះ លក្ខន្តិកៈរបស់តុលាការ ICC បានបែងចែកដាច់ពីគ្នាស្រឡះរវាងជម្លោះប្រដាប់អាវុធអន្តរជាតិ និង ជម្លោះដែលមិនមានលក្ខណៈជាអន្តរជាតិ។ នៅតុលាការ ICC អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរអាច<u>ត្រឹម</u>តែយកទៅអនុវត្តបាន នៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ។ ករណីនេះត្រូវបានបញ្ជាក់តាមរយៈអត្ថបទ ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការពង្រាងច្បាប់លក្ខន្តិកៈរបស់ ICC[34] ។

១៣. តុលាការ ICTY ក៏បានបញ្ជាក់ច្បាស់អំពី អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរដែរ គឺថាត្រឹមតែអាចយកទៅអនុវត្តបាននៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ។ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Tadić* បានតម្កល់ថា៖ "នៅក្នុងស្ថានភាពបច្ចុប្បន្ននៃការវិវត្តន៍ផ្នែកច្បាប់ [អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ] ត្រឹមតែអាចអនុវត្តបានចំពោះបទល្មើសដែលប្រព្រឹត្តនៅក្នុងបរិបទ នៃជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ"[35]។ តុលាការ ICTY ក៏បានបញ្ជាក់ទៅលើសេចក្តីសម្រេចនេះម្តងហើយម្តងទៀត[36]។

---

[32] ពាក្យថា "ការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់និងទម្លាប់ជាធរមាននៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ" គឺជា "ការច្របូកច្របល់ខុសប្លែកពីធម្មតានៃសញ្ញាណចាស់ៗរបស់ "ច្បាប់ ឬ ទម្លាប់ សង្គ្រាម"។ Knut Dörmann, **សេចក្តីអធិប្បាយទៅលើលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ៖ កំណត់សម្គាល់របស់អ្នកសង្កេតការណ៍៖ ពីអត្ថបទមួយទៅអត្ថបទមួយ** 322, 323 (O. Triffterer (ed.) ឆ្នាំ២០០៨) (គូសបញ្ជាក់បន្ថែម)។

[33] គូសបញ្ជាក់បន្ថែម។

[34] "អំពើដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងបរិបទ និងជាបរិបទនៃ និងដែលមានជាប់ពាក់ព័ន្ធជាមួយជម្លោះប្រដាប់អាវុធអន្តរជាតិ" KNUT DÖRMANN, ELEMENTS OF WAR CRIMES UNDER THE ROME STATUTE OF THE INTERNATIONAL CRIMINAL COURT ("DÖRMANN") 17 (Cambridge University Press, 2002).។

[35] សេចក្តីសម្រេចទៅលើយុត្តាធិការក្នុងរឿងក្តី *Tadić* កថាខណ្ឌ៨៤។

[36] "ដើម្បីឱ្យតុលាការអន្តរជាតិផ្តន្ទាទោសដល់ជនណាម្នាក់ ចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវបានតាមមាត្រា២ នៃលក្ខន្តិកៈនេះ បទល្មើសត្រូវតែបានប្រព្រឹត្តឡើង *ពោលគឺ៖* (i).<u>នៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិ</u>" *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blaškić* សំណុំរឿងលេខ IT-95-14-A សាលក្រម ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤

១៤. បទប្បញ្ញត្តិនានានៅក្នុងលក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ("ICTR") ឬ តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ("SCSL") ចែងអំពី អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ នេះទេ។ ទាំងតុលាការ ICTR និង តុលាការ SCSL សុទ្ធតែមានយុត្តាធិការទៅលើជម្លោះប្រដាប់អាវុធដែលមិនមែនជាអន្តរជាតិ[37]។

## គ. ត្រូវមានចំណងទាក់ទងរវាងអំពើដែលមានចែងក្នុងច្បាប់ និង ជម្លោះប្រដាប់អាវុធអន្តរជាតិ

១៥. លក្ខខណ្ឌតម្រូវនៃទំនាក់ទំនងគឺមានលក្ខណៈចំបាច់ ដើម្បីឲ្យអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរត្រូវបញ្ចូលនូវការរំលោភច្បាប់មនុស្សធម៌អន្តរជាតិ តែ ជាឧទាហរណ៍ ត្រូវដកចេញនូវបទឧក្រិដ្ឋកម្មក្នុងស្រុក។ តាមលក្ខណៈតក្កវិជ្ជា ប្រសិនបើអំពើដែលមានចែងក្នុងច្បាប់នោះមិនទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធអន្តរជាតិទេ ក៏មិនមានការរំលោភដល់ច្បាប់មនុស្សធម៌អន្តរជាតិដែរ។ តុលាការ ICTY បានអនុវត្តតាមសំអាងហេតុបែបនេះ[38]។ អ.វ.ត.ក គួរតែដើរតាមមាគ៌ានេះដែរ។

១៦. តុលាការ ICTY បានសម្រេចថា បុរេលក្ខខណ្ឌមួយក្នុងចំណោមបុរេលក្ខខណ្ឌនានាដែលអាចអនុវត្តបានចំពោះ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរនោះគឺ៖ "ការបង្កើតទំនាក់ទំនងរវាងបទឧក្រិដ្ឋកម្ម និង ជម្លោះប្រដាប់អាវុធ"[39]។ លក្ខខណ្ឌចាំបាច់នៃចំណងទាក់ទងទាមទារឲ្យមាន ទំនាក់ទំនងផ្នែក

---

កថាខណ្ឌ១៧០ (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Brđanin* សំណុំរឿងលេខ IT-99-36-T សាលក្រម ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៣ ("សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្ដី *Brđanin*") កថាខណ្ឌ១២១។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Simić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-95-9-T សាលក្រម ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ១០៦។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Naletilić និង Martinović* សំណុំរឿងលេខ IT-98-34-T សាលក្រម ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ("សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្ដី *Naletilić*") កថាខណ្ឌ១៧៦។

[37] ជំនួសមកវិញ តុលាការ ICTR និង តុលាការ SCSL បានកំណត់ជាបទល្មើសព្រហ្មទណ្ឌចំពោះ "ការរំលោភយ៉ាងធ្ងន់ធ្ងរ" ទៅលើមាត្រា៣រួម នៃអនុសញ្ញាទីក្រុងហ្សឺណែវ និង ពិធីសារបន្ថែមទី II (លក្ខន្តិកៈតុលាការ ICTR មាត្រា៤ លក្ខន្តិកៈតុលាការ SCSL មាត្រា៣)។ ក៏ប៉ុន្តែ ដូចបានពន្យល់រួចមកហើយនៅក្នុង សំណើសុំទីមួយស្ដីពីអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ថា ឧក្រិដ្ឋកម្មសង្គ្រាមដែលមិនមែនជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ មិនអាចយកមកអនុវត្ត) អ.វ.ត.ក បានទេ។

[38] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្ដី *Tadić* កថាខណ្ឌ៥៧២។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Delalić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96-21-T សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ កថាខណ្ឌ១៩៣។

[39] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្ដី *Brđanin* កថាខណ្ឌ១២១។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Kordić និង Čerkez* សំណុំរឿងលេខ IT-95-14/2-T សាលក្រម ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ ("សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្ដី *Kordić*") កថាខណ្ឌ៣២។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Blaškić* សំណុំរឿងលេខ IT-95-14-T សាលក្រម ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ៦៩។

00526304



ភូមិសាស្ត្រ និង ពេលវេលា រវាងអំពើរបស់ជនជាប់ចោទ និង ជម្លោះប្រដាប់អាវុធ៖ "វាមានលក្ខណៈគ្រប់គ្រាន់ដែលថា បទឧក្រិដ្ឋកម្មនោះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹង អំពើអរិភាពដែលបានកើតឡើងនៅលើផ្នែកខ្លះនៃទឹកដីដែលស្ថិតក្រោមការកាន់កាប់ដោយភាគីជម្លោះ"[40]។

១៧. អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានដាក់លក្ខខណ្ឌតម្រូវខ្ពស់សម្រាប់ចំណងទាក់ទងរវាងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងជម្លោះអន្តរជាតិ ដូចជាការកំណត់ថា "អត្ថិភាពនៃជម្លោះប្រដាប់អាវុធមួយ ក្នុងកម្រិតអប្បបរមា ត្រូវតែបានរួមចំណែកសំខាន់ នៅក្នុងលទ្ធភាពរបស់ចារីក្នុងការប្រព្រឹត្តិ [អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ], ការសម្រេចចិត្តរបស់ចារីក្នុងការប្រព្រឹត្តិការរំលោភបំពាននោះ, វិធីនៃការប្រព្រឹត្តិ ឬគោលបំណងនៃការប្រព្រឹត្តិ"[41]។ លក្ខខណ្ឌតម្រូវនេះមានលក្ខណៈចាំបាច់សម្រាប់ "កំណត់ភាពខុសគ្នារវាងឧក្រិដ្ឋកម្មសង្គ្រាម និងបទល្មើសជាតិ"[42]។ "ការរួមចំណែកសំខាន់" ចង់សំដៅថាជម្លោះប្រដាប់អាវុធត្រូវដើរតួនាទីសំខាន់នៅក្នុងលទ្ធភាពរបស់ជនត្រូវចោទក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ការណ៍ដែលគ្រាន់តែមាន "ការរួមចំណែកខ្លះ" នឹងពុំធ្វើឱ្យឧក្រិដ្ឋកម្មក្លាយជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរឡើយ។

១៨. ជនត្រូវចោទត្រូវដឹងឮអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានបញ្ជាក់ថា "ខ្លួនជឿជាក់ថា [ជនត្រូវចោទ] ពិតជាបានដឹងអំពីកាលៈទេសៈជាក់ស្តែង ដូចជា កាលៈទេសៈមួយដែលរដ្ឋបរទេសមួយបានជាប់ពាក់ព័ន្ធនៅក្នុងជម្លោះប្រដាប់អាវុធជាដើម"[43]។ បើគ្មានការដឹងឮនេះទេ គេពុំអាចចាត់ទុកឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរបានឡើយ។

---

[40] សេចក្តីសម្រេចលើយុត្តាធិការលើរឿងក្តី *Tadić* កថាខណ្ឌ៧០។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Naletilić* កថាខណ្ឌ១៧៧។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Brđanin* កថាខណ្ឌ១២៣។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Krnojelac សំណុំរឿងលេខ IT-97-25-T សាលក្រម ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២00២ កថាខណ្ឌ៥១។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Kunarac *និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96-23-T និង IT-96-23/1-T សាលក្រម ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២00១ ("សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើរឿងក្តី *Kunarac*") កថាខណ្ឌ៤0២។

[41] *រដ្ឋអាជ្ញា ទល់នឹង* Kunarac *និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96-23 និង IT-96-23/1-A, សាលដីកា, ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២00២ (សាលដីកាបណ្តឹងឧទ្ធរណ៍ក្នុងរឿងក្តី Kunarac")។ កថាខណ្ឌ ៥៨។

[42] *ដូចជើងទំព័រខាងលើ។*

[43] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង* Kordic *និង* Cerkez, សំណុំរឿងលេខ IT-95-14/2-A, សាលដីកា, ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២00៤, កថាខណ្ឌ ៣១១ (គូសបញ្ជាក់តាមសំណៅដើម)។

១៩. គេត្រូវពិចារណានូវលក្ខណៈវិនិច្ឆ័យចំនួន២ បន្ថែមទៀត។ ទីមួយ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ អាចយកមកអនុវត្តបាន "រហូតដល់មានការបញ្ឈប់សកម្មភាពប្រយុទ្ធគ្នាក្នុងតំបន់ណាមួយ"[44] តែប៉ុណ្ណោះ។ ទីពីរ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរកើតឡើង ប្រសិនបើ "គេបានប្រព្រឹត្តវាដើម្បីជម្រុញ ឬកេងចំណេញពីសភាពការណ៍ដែលបណ្តាលមកពីការវាយប្រយុទ្ធគ្នា"[45] ប៉ុណ្ណោះ។ ប្រសិនបើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ពុំបានបំពេញតាមលក្ខខណ្ឌតម្រូវទាំង២នេះទេ ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ពុំមែនជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរឡើយ។

២០. អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានលើកឡើងនូវកត្តាមួយចំនួន*ក្នុងចំណោមកត្តាផ្សេងៗ* ដែលគេអាចយកមកពិចារណាដើម្បី បញ្ជាក់អំពីចំណងទាក់ទងរវាងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ និងជម្លោះអន្តរជាតិ ដែលមាន ដូចជា៖

> ការពិតដែលថាចារីគឺជាយុទ្ធជន, ការពិតដែលថាជនរងគ្រោះពុំមែនជាយុទ្ធជន, ការពិតដែលថាជនរងគ្រោះគឺជាសមាជិកនៃភាគីបដិបក្ខ, ការពិតដែលថាអំពើនោះអាចត្រូវបានគេនិយាយថា វាបម្រើដល់គោលដៅស្ពាពរនៃយុទ្ធនាការយោធា, និងការពិតដែលថាឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តជាផ្នែកមួយ ឬក្នុងបរិបទមួយនៃភារកិច្ចផ្លូវការរបស់ចារី[46]។

២១. តុលាការ ICC បានយកលំនាំតាមយុត្តិសាស្ត្ររបស់តុលាការ ICTY ដោយតម្រូវអោយមានចំណងទាក់ទងរវាង៖ "ធាតុផ្សំនៃបទល្មើសដែលតម្រូវថា អំពើដែលត្រូវបានប្រព្រឹត្តជាបរិបទនៃ និងដែលមានជាប់ពាក់ព័ន្ធជាមួយជម្លោះប្រដាប់អាវុធ"[47]។ គណៈកម្មាធិការពង្រាងច្បាប់លក្ខន្តិកៈរបស់ ICC បានថ្លែងបន្ថែមទៀតថា ជនជាប់ចោទត្រូវតែដឹងថា ជនរងគ្រោះជាសមាជិកនៃភាគីបដិបក្ខ[48]។

---

[44] សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ៥៦៨។

[45] *ដូចដើងទំព័រខាងលើ។*

[46] សាលដីកាអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ៥៩។

[47] *រឿងក្តីរដ្ឋអាជ្ញា តតាំងនឹង* Thomas Lubanga Dyilo សំណុំរឿងលេខ ICC-01/04-01/06 អង្គបុរេជំនុំជម្រះ I សេចក្តីសម្រេចលើការទទួលស្គាល់ការចោទប្រកាន់ ចុះថ្ងៃទី ២៩ មករា ២០០៧ ("សេចក្តីសម្រេចទទួលស្គាល់ការចោទប្រកាន់ *Lubanga*") កថាខណ្ឌ ២៨៦ ដែលត្រូវបានទទួលយកដោយ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Germain Katanga* សំណុំរឿងលេខ ICC-01/04-01/07 អង្គបុរេជំនុំជម្រះ I សេចក្តីសម្រេចលើការទទួលស្គាល់ការចោទប្រកាន់ ចុះថ្ងៃទី ៣០ កញ្ញា ២០០៨ ("សេចក្តីសម្រេចទទួលស្គាល់ការចោទប្រកាន់ *Katanga*") កថាខណ្ឌ ៣៧៩។

[48] DÖRMANN, ទំព័រ ២៩។

២២. ប្រសិនបើអំពើបំពារបំពានធ្ងន់ធ្ងរត្រូវបានគេរកឃើញថា អាចយកមកអនុវត្តបាននៅ អ.វ.ត.ក លក្ខខណ្ឌតម្រូវចាំបាច់ ក្នុងការបញ្ជាក់ទំនាក់ទំនងរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធអន្តរជាតិ គឺជាលក្ខខណ្ឌមួយដ៏ខ្ពស់ ដូចសំណុំរឿងនៅតុលាការ ICTY និងតុលាការ ICC ដែរ។ ប្រសិនបើគេពុំបាន បំពេញតាមលក្ខខណ្ឌតម្រូវខាងលើនោះទេ គេពុំអាចបញ្ជាក់អំពីចំណងទាក់ទងរវាងអំពីជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធអន្តរជាតិបានឡើយ។

**ឃ. ជនរងគ្រោះដោយសារអំពើជាមូលដ្ឋាន ត្រូវមានឋានៈជាបុគ្គល ឬទ្រព្យសម្បត្តិដែលទទួលបានការការពារ អនុលោមតាមអនុសញ្ញាទីក្រុងហ្សឺណែវ និងច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក**

២៣. អនុលោមតាមអនុសញ្ញាទីក្រុងហ្សឺណែវ មាត្រា ៤(១) នៃអនុសញ្ញាទី IV បានកំណត់និយមន័យបុគ្គលដែលទទួលបានការការពារថាជា "បុគ្គលដែលទទួលបានការការពារពីសំណាក់អនុសញ្ញានេះ គឺជាមនុស្សទាំងឡាយណាដែលយល់ឃើញថា ខ្លួនស្ថិតនៅក្នុងកណ្តាប់ដៃរបស់ភាគីមួយនៃជម្លោះ ឬក្រោមសិទ្ធិអំណាចត្រួតត្រារបស់ប្រទេសមួយដែលពុំមែនជាប្រទេសរបស់ខ្លួន ទោះស្ថិតក្នុងពេលវេលា និងកាលៈទេសៈណាក្តី ក្នុងករណីមានជម្លោះ ឬការឈ្លានពាន"។ សេចក្តីពន្យល់នៃអនុសញ្ញាទីក្រុងហ្សឺណែវ បានរៀបរាប់អំពីបុគ្គលដែលទទួលការការពារ ចំនួន២ប្រភេទ៖ "(១) "ជនជាតិរបស់សត្រូវ" ដែលស្ថិតនៅក្នុងទឹកដីជាតិរបស់ភាគីនីមួយៗ នៃជម្លោះ និង(២) "ប្រជាជនទាំងអស់" នៃទឹកដីដែលត្រូវបានត្រួតត្រា (មិនរាប់បញ្ចូលជនជាតិរបស់ប្រទេសត្រួតត្រាឡើយ"[49]។ ក្នុងការកំណត់មាត្រា៤(១) នៃអនុសញ្ញាទី IV សេចក្តីពន្យល់នៃអនុសញ្ញាទីក្រុងហ្សឺណែវគូសបញ្ជាក់ថា៖

> និយមន័យត្រូវបានកំណត់ក្នុងទម្រង់អវិជ្ជមាន ក្នុងគោលបំណងដាក់បញ្ចូលជនទាំងឡាយណាដែល "ពុំមែនជា" ជនជាតិនៃភាគីជម្លោះ ឬប្រទេសត្រួតត្រា ដែលខ្លួនកំពុងស្ថិតនៅក្រោម។ ដូច្នេះអនុសញ្ញានេះនៅតែស្របជាមួយគោលការណ៍ច្បាប់អន្តរជាតិដែលបានការទទួលស្គាល់។ វាពុំជ្រៀតជ្រែកចូលទំនាក់ទំនងរបស់រដ្ឋមួយ ជាមួយនឹងជនជាតិរបស់រដ្ឋនោះឡើយ[50]។

---

[49] អនុសញ្ញាទី IV, មាត្រា ៤(១)។

[50] សេចក្តីពន្យល់នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV, មាត្រា ៤(១) ដែលមានដាក់នៅគេហទំព័រ http://www.icrc.org/ihl.nsf/COM/380-600007?OpenDocument។

00526307



២៤. សេចក្តីពន្យល់នៃមាត្រា៤(១) ពន្យល់បន្ថែមថា មាត្រា៤(១) តម្រូវឲ្យមានការដកបុគ្គលមួយចំនួនដូចខាងក្រោម ចេញពីឋានៈជាបុគ្គលដែលទទួលបានការការពារ៖

ក. នៅក្នុងទឹកដីរបស់រដ្ឋបច្ចាមិត្ត៖ ការការពារត្រូវបានផ្តល់ឲ្យតាមមាត្រា៤ ទៅឲ្យបុគ្គលគ្រប់រូបដែលមានសញ្ជាតិបរទេស និងបុគ្គលដែលគ្មានសញ្ជាតិ។ ប៉ុន្តែពុំរាប់បញ្ចូលមនុស្សមួយចំនួនដូចខាងក្រោម៖

(១) ជនជាតិរបស់រដ្ឋមួយដែលពុំជាប់កាតព្វកិច្ចតាមរយៈអនុសញ្ញានេះ

(២) ជនជាតិរបស់រដ្ឋអព្យាក្រឹតមួយ ឬរដ្ឋបច្ចាមិត្ត ប្រសិនបើរដ្ឋនោះមានតំណាងការទូតនៅក្នុងរដ្ឋដែលប្រជាជនរបស់ខ្លួនស្ថិតនៅ

(៣) បុគ្គលដែលស្ថិតនៅក្នុងនិយមន័យខាងលើ ត្រង់ចំណុច (ក) ដែលទទួលបានការការពារតាមអនុសញ្ញាទីក្រុងហ្សឺណែវមួយ ក្នុងចំណោមអនុសញ្ញា៣ផ្សេងទៀត ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩។

ខ. នៅក្នុងទឹកដីដែលត្រូវបានឈ្លានពានត្រួតត្រា៖ ការការពារត្រូវបានផ្តល់ទៅឲ្យរាល់គ្រប់បុគ្គលទាំងអស់ ដែលពុំមែនជាជនជាតិនៃរដ្ឋត្រួតត្រានោះ។ ប៉ុន្តែពុំរាប់បញ្ចូលមនុស្សមួយចំនួនដូចខាងក្រោម៖

(១) ជនជាតិនៃរដ្ឋមួយដែលពុំមែនជាភាគីនៃអនុសញ្ញា

(២) ជនជាតិនៃរដ្ឋបច្ចាមិត្ត ប្រសិនបើរដ្ឋនោះមានតំណាងការទូតធម្មតា នៅក្នុងរដ្ឋត្រួតត្រា

(៣) បុគ្គលដែលស្ថិតនៅក្នុងនិយមន័យខាងលើ ត្រង់ចំណុច ខ ដែលទទួលបានការការពារតាមអនុសញ្ញាទីក្រុងហ្សឺណែវមួយ ក្នុងចំណោមអនុសញ្ញា៣ផ្សេងទៀត ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩។

ដូច្នេះ អនុសញ្ញាទីក្រុងហ្សឺណែវ និងសេចក្តីពន្យល់នៃអនុសញ្ញាទីក្រុងហ្សឺណែវ បញ្ជាក់ច្បាស់ថាបុគ្គលដែលទទួលបានការការពារគឺត្រូវបានកំណត់ដោយសញ្ជាតិរបស់ពួកគាត់។

២៥. មកទល់ខែមិថុនា ឆ្នាំ១៩៩៩ តុលាការ ICTY បានកំណត់និយមន័យបុគ្គលដែលទទួលបានការការ

ពារផ្អែកតាមសញ្ជាតិរបស់ពួកគាត់[51]។ ទើបតែនៅក្នុងខែកក្កដា ឆ្នាំ១៩៩៩ ទើបអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានពង្រីកនិយមន័យនៃពាក្យថា "ជនជាតិ" ឲ្យទៅជាបុគ្គលដែលស្ថិតក្នុងក្រុមជាតិពន្ធុខុសៗគ្នា[52]។ អ.វ.ត.ក មានយុត្តាធិការក្នុងពេលវេលា ទៅលើរយៈកាលពីឆ្នាំ១៩៧៥-១៩៧៩ ដែលកាលនោះគេពុំអាចដឹងមុន ឬពិនិត្យមើលនូវនិយមន័យទូលាយនេះបានទេ។ និយមន័យទូលាយរបស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY ចំពោះបុគ្គលដែលទទួលបានការការពារ ពុំអាចត្រូវបានយកមកអនុវត្តនៅ អ.វ.ត.ក បានទេ ដោយហេតុថាវានឹងរំលោភលើគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង*។ និយមន័យនៃពាក្យថាបុគ្គលដែល ទទួលបានការការពារនៅ អ.វ.ត.ក ត្រូវរាប់បញ្ចូលតែបុគ្គលណាដែលទទួលបានការការពារផ្អែកតាមសញ្ជាតិរបស់ពួកគាត់តែប៉ុណ្ណោះ។

២៦. និយមន័យទូលាយនៃបុគ្គលដែលទទួលបានការការពារពុំមានអត្ថិភាពឡើយ ទើបតែពេលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានតាក់តែងនិយមន័យនេះក្នុងខែកក្កដា ឆ្នាំ១៩៩៩ ប៉ុណ្ណោះ។ និយមន័យទូលាយត្រូវបានតាក់តែងឡើងដោយហេតុថា "វិធីសាស្ត្រគតិយុត្តិដែលឲ្យតម្លៃទំនាក់ទំនងសំខាន់ខ្លាំងជាងចំណងផ្លូវការនោះ កាន់តែមានសារសំខាន់នៅក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិនាពេលបច្ចុប្បន្ន"[53]។ នៅក្នុងការកំណត់ "ជម្លោះប្រដាប់អាវុធអន្តរជាតិនាពេលបច្ចុប្បន្ន" អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានគូសបញ្ជាក់ថា "ទោះបីពីមុន សង្គ្រាមបានកើតឡើងរវាង រដ្ឋដែលបានការទទួលស្គាល់ត្រឹមត្រូវក្តី ប៉ុន្តែសព្វថ្ងៃជម្លោះប្រដាប់អាវុធអន្តរជាតិពន្ធុ ដូចជានៅអតីតយូហ្គោស្លាវី <u>រដ្ឋថ្មីៗតែងត្រូវបានបង្កើតឡើងក្នុងអំឡុងពេលមានជម្លោះ</u> ហើយវាគឺជាបញ្ហាជាតិពន្ធុ ពុំមែនសញ្ជាតិទេ ដែលបានក្លាយទៅជាមូលដ្ឋាននៃចំណងកាតព្វកិច្ច"[54]។ ដូច្នេះអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានយកនិយមន័យទូលាយនៃសញ្ជាតិនេះមកអនុវត្តតែនៅក្នុងបរិបទនៃការបង្កើតរដ្ឋថ្មីដែលអាចមាន ក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិពន្ធុនាពេលបច្ចុប្បន្នប៉ុណ្ណោះ។ លើកលែងតែមាន<u>ការបង្កើតរដ្ឋថ្មីណាមួយដែលអាចកើតឡើង</u> ក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិពន្ធុនាពេលបច្ចុប្បន្ន ទើបគេត្រូវយកនិយមន័យចង្អៀតស្តីពីជនជាតិមកអនុវត្ត ដូចដែលបាន

---

[51] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Aleksovski*, សំណុំរឿងលេខ IT-95-14/1-T, សាលក្រម, ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៩ កថាខណ្ឌ៤៦។

[52] *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Tadic*, សំណុំរឿងលេខ IT-94-1-A, សាលដីកា, ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ១៦៦។

[53] ដូចជើងទំព័រខាងលើ។

[54] ដូចជើងទំព័រខាងលើ (គូសបញ្ជាក់បន្ថែម)។

ការទទួលស្គាល់ក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ និងសេចក្តីពន្យល់របស់វា។

២៧. គណៈកម្មាធិការពង្រាងច្បាប់លក្ខន្តិកៈរបស់ ICC បានបន្ថែមធាតុផ្សំអត្តនោម័តទៅលើនិយមន័យនៃជនដែលទទួលបានការការពារ គឺថា ជនជាប់ចោទត្រូវតែដឹងថាជនរងគ្រោះគឺជាសមាជិកនៃភាគីបដិបក្ខ[55]។ គណៈកម្មាធិការពង្រាងច្បាប់លក្ខន្តិកៈរបស់ ICC គឺជាគណៈប្រតិភូរបស់បណ្តារដ្ឋដែលបានជួយដល់ការតាក់តែងធាតុផ្សំនៃបទល្មើសនៅតុលាការ ICC។ ហេតុដូច្នេះ បណ្តារដ្ឋទាំងនោះបានសំដែងនូវ *opinio jurist* នៃសហគមន៍អន្តរជាតិដែលត្រូវយកមកអនុវត្តនៅតុលាការ ICC។ នៅពេលដែលច្បាប់អាចត្រូវបានបកស្រាយដើម្បីជាប្រយោជន៍ដល់ជនជាប់ចោទ ច្បាប់នោះដាច់ខាតត្រូវតែធ្វើការបកស្រាយនៅក្នុងរបៀបបែបនោះ។ ករណីនេះគឺសមស្របទៅតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនសង្ស័យ* (*in dubio pro reo*) ដូចដែលមានចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

**ង. *ចេតនាឧក្រិដ្ឋ* ចាំបាច់សម្រាប់បទល្មើសនៃអំពើបំពារបំពានធ្ងន់ធ្ងរ គឺជាចេតនា ឬការព្រហើន ក្រោមកាលៈទេសៈជាក់លាក់ណាមួយ**

២៨. មាត្រា ៣០(១) នៃលក្ខន្តិកៈតុលាការ ICC ចែងពាក់ព័ន្ធនឹង "ធាតុផ្សំផ្នែកចិត្តសាស្ត្រ" សម្រាប់បទល្មើសនានាដែលត្រូវបានដាក់បញ្ចូលនៅក្នុងលក្ខន្តិកៈរបស់ខ្លួន ដូចតទៅនេះ "ប្រសិនបើពុំមានចែងផ្សេងពីនេះ បុគ្គលម្នាក់ត្រូវមានទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងអាចផ្តន្ទាទោសបានចំពោះឧក្រិដ្ឋកម្មមួយដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ ប្រសិនបើធាតុផ្សំអត្តនោម័តត្រូវបានប្រព្រឹត្តដោយចេតនា និងដោយមានការដឹងឮ"[56]។ តុលាការ ICC ជឿជាក់ថាការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួន អាចត្រូវបានដាក់ទៅលើជនត្រូវចោទនៅពេលជនត្រូវចោទមានចេតនា និងមានការដឹងឮអំពីឧក្រិដ្ឋកម្ម។ តុលាការ ICC ពុំបានលើកឡើងនូវពាក្យថា "ការធ្វេសប្រហែស" ឡើយ។ ដូចគ្នានេះ អ.វ.ត.ក ក៏ពុំអាចចោទជនត្រូវចោទពីបទបំពារបំពានធ្ងន់ធ្ងរផ្អែកលើការធ្វេសប្រហែសនេះបានឡើយ។

២៩. អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានបញ្ជាក់ថា "*ចេតនាឧក្រិដ្ឋ* ដែលជាចំណែកធាតុផ្សំនៃការរំលោភបំពាន [បទល្មើសនៃការបំពារបំពានធ្ងន់ធ្ងរ] រួមមានទាំងចេតនាពិរុទ្ធ និង

[55] DÖRMANN, ទំព័រ ២៩។

[56] លក្ខន្តិៈតុលាការ ICC មាត្រា ៣០(១)។

ការព្រហើន ដែលអាចត្រូវបានប្រៀបធៀបទៅនឹងប្រមាថធ្ងន់ធ្ងរចំពោះឧក្រិដ្ឋកម្ម"[57]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានបង្កើតកំហុសឆ្គងចំនួន២។ កំហុសទី១ ការព្រហើន និងការធ្វេសប្រហែសធ្ងន់ធ្ងរចំពោះឧក្រិដ្ឋកម្ម គឺពុំដូចគ្នាទេ។ តាមបទដ្ឋានគតិយុត្តិ ពាក្យទាំង២នេះខុសគ្នាស្រឡះ។ វចនានុក្រម Black's Law បានកំណត់និយមន័យពាក្យថា "ការធ្វេសប្រហែស" ថាជា "ការខកខានពុំបានអនុវត្តបទដ្ឋាននៃការយកចិត្តទុកដាក់ ដែលមនុស្សស្គាល់ហេតុផលដឹងខុសត្រូវ នឹងយកមកអនុវត្តនៅក្នុងសភាពការណ៍ស្រដៀងគ្នានេះ..."[58] ។ រីឯពាក្យថា "ការព្រហើន" ត្រូវបានផ្តល់និយមន័យថាជា "អំពើដែលអ្នកប្រព្រឹត្តពុំមានបំណងបង្កឱ្យមានផលវិបាកអន្តរាយ ប៉ុន្តែអ្នកប្រព្រឹត្តដឹងមុននូវលទ្ធភាពនៃផលវិបាកនោះ និងនៅតែស្ម័គ្រចិត្តប្រថុយនឹងហានិភ័យនៃផលវិបាកនោះ...។ ការព្រហើនពាក់ព័ន្ធនឹងកំហុសក្នុងកម្រិតខ្ពស់ជាងការធ្វេសប្រហែស ប៉ុន្តែកម្រិតនៃកំហុសមានទាបជាងការប្រព្រឹត្តខុសដោយចេតនា"[59]។ សូម្បីតែក្នុងករណី មានការធ្វេសប្រហែសក្នុងលក្ខណៈធ្ងន់ធ្ងរក្តី ក៏តុលាការពុំប្រដូចវាទៅនឹងការព្រហើនដែរ[60]។ ដូច្នេះ លក្ខខណ្ឌតម្រូវក្នុងការ បញ្ជាក់អំពីការធ្វេសប្រហែស គឺទាបជាងលក្ខខណ្ឌតម្រូវក្នុងការបញ្ជាក់អំពីការព្រហើន។ កំហុសឆ្គងទី២ ភាពធ្ងន់ធ្ងរនៃការបំពារបំពានធ្ងន់ធ្ងរពុំអាចផ្តល់យុត្តិកម្មដល់បទដ្ឋាន *ចេតនាឧក្រិដ្ឋ* នៃការធ្វេសប្រហែសបានឡើយ។ Jones និង Powles បានសង្ខេបគំនិតនេះ យ៉ាងខ្លីថា៖

> ទោះបីជាយ៉ាងដូច្នេះក្តី ការយោងទៅលើការធ្វេសប្រហែសនេះជាការគួរឱ្យភ្ញាក់ផ្អើល។ យើងពុំរំពឹងទុកថាជនត្រូវចោទដែលគ្រាន់តែពុំបានធ្វេសប្រហែសធម្មតា ឬធ្ងន់ធ្ងរនោះ ត្រូវបានតុលាការ ICTY ផ្តន្ទាទោសពី "បទរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ" ឡើយ។ អង្គជំនុំជម្រះ ប្រហែលកំពុងគិតអំពីការទទួលខុសត្រូវតាមមាត្រា៧(៣) នៃលក្ខន្តិកៈតុលាការ ICTY ដែលអាចត្រូវបានចាត់ទុកថាជាការបង្កើតការទទួលខុសត្រូវសម្រាប់មេបញ្ជាការចំពោះការធ្វេសប្រហែស ក្រោមកាលៈទេសៈណាមួយ។ ប៉ុន្តែ បញ្ហានេះជាបញ្ហាមួយដោយឡែកពីលក្ខខណ្ឌតម្រូវនៃ *ចេតនាឧក្រិដ្ឋ* ចាំបាច់សម្រាប់ការទទួលខុសត្រូវតាម

---

[57] សាលក្រមអង្គជំនុំជម្រះក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ១៥២។

[58] វចនានុក្រម Black's Law 1056 (ការប្រែសម្រួលលោកទី៧ ឆ្នាំ១៩៩៩)។

[59] វចនានុក្រម Black's Law 1277 (ការប្រែសម្រួលលោកទី៧ ឆ្នាំ១៩៩៩)។

[60] "ប៉ុន្តែ ជាការពិតដែលថាតុលាការភាគច្រើនចាត់ទុក "ការធ្វេសប្រហែសធ្ងន់ធ្ងរ" ពុំមានការព្រហើន ដោយពុំគិតអំពីផលវិបាក ហើយ ការធ្វេសប្រហែសធ្ងន់ធ្ងរ និងការធ្វេសប្រហែសធម្មតា ខុសគ្នាត្រង់កម្រិត ពុំមែនខុសគ្នាត្រង់ប្រភេទឡើយ"។ វចនានុក្រម Black's Law 1057 (ការប្រែសម្រួលលោកទី៧ ឆ្នាំ១៩៩៩)។ ដោយដកស្រង់យកសម្តី W.Page Keeton, Prosser and Keeton on The Law of Torts 211-12 (ការប្រែសម្រួលលោកទី៥ ឆ្នាំ១៩៨៤)។

00526311



មាត្រា២នៃលក្ខន្តិកៈ ហើយគេបានអះអាងថាការធ្វេសប្រហែសណាមួយនឹងពុំបំពេញតាមលក្ខខណ្ឌតម្រូវនេះឡើយ។ មានតែចេតនា ឬការព្រហើនក្រោមកាលៈទេសៈណាមួយប៉ុណ្ណោះ ដែលគ្រប់គ្រាន់សម្រាប់ធ្វើជាមូលដ្ឋាននៃបទចោទអំពី "អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ" ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ[61]។

អ.វ.ត.ក អាចត្រឹមតែផ្តន្ទាទោសជនត្រូវចោទដោយផ្អែកតាម ចេតនាប្រព្រឹត្ត ឬ ការធ្វេសប្រហែសក្រោមកាលៈទេសៈណាមួយ ប៉ុណ្ណោះ[62]។

៣០. ប្រសិនបើទម្រង់នៃការទទួលខុសត្រូវទាំងនេះត្រូវបានយកមកអនុវត្តនៅ អ.វ.ត.ក ការទទួលខុសត្រូវដែលចេញមកពី *ចេតនាឧក្រិដ្ឋ* នៃការទទួលខុសត្រូវរបស់ថ្នាក់លើ/មេបញ្ជាការ ឬ JCE គឺជាបញ្ហាមួយដាច់ដោយឡែកពីបញ្ហា *ចេតនាឧក្រិដ្ឋ* ចាំបាច់សម្រាប់អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ[63]។ ដើម្បីឱ្យអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរកើតឡើង តុលាការត្រូវបង្ហាញថាចារីបានប្រព្រឹត្តឧក្រិដ្ឋកម្មដោយមានចេតនា ឬដោយការព្រហើន។ បញ្ហាស្តីពី *ចេតនាឧក្រិដ្ឋ* របស់អ្នកចូលរួមក្នុង JCE ឬរបស់ថ្នាក់លើ/ មេបញ្ជាការនឹងត្រូវលើកយកមកកំណត់ដាច់ដោយឡែកពីគ្នា។

៣១. មាត្រា ៦ នៃច្បាប់បង្កើត អ.វ.ត.ក កំណត់ការអនុវត្តចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរត្រឹម "ជនសង្ស័យទាំងអស់ ដែលបានប្រព្រឹត្ត ឬបានបញ្ជា"។ ទម្រង់ទទួលខុសត្រូវផ្សេងៗទៀត ដែលគ្មានចែងក្នុងមាត្រា ២៩ នៃច្បាប់បង្កើត អ.វ.ត.ក ដូចជាសហកម្មឧក្រិដ្ឋកម្មជាដើមគឺមិនអាចយកមកអនុវត្ត ចំពោះបទឧក្រិដ្ឋអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរបានទេ។

## ឆ. និយមន័យនៃពាក្យ អំពើដែលមានចែងក្នុងច្បាប់

៣២. លទ្ធភាពក្នុងការលើកយកមកពិភាក្សានូវ រាល់ធាតុផ្សំដែលមានសម្រាប់គ្រប់បទល្មើសទាំងអស់ដែលអាចបង្កើតបានជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរមួយនោះ មិនអាចធ្វើទៅបានទេ អាស្រ័យដោយចំនួនទំព័រមានកម្រិត។ ក៏ប៉ុន្តែ មេធាវីការពារក្តីកត់សម្គាល់ថា ធាតុផ្សំនៃបណ្តាបទល្មើស ត្រូវតែយកមកអនុវត្តទៅតាមការកំណត់ក្នុងចន្លោះឆ្នាំ១៩៧៥-៧៩ដើម្បីឱ្យស្ថិតនៅក្រោមយុត្តាធិការ របស់ អ.វ.ត.ក។

[61] Jones and Powles, International Criminal Practice 246 (Oxford University Press ឆ្នាំ២០០៣)។

[62] សូមមើលកថាខណ្ឌ ៣០-៣៩ សូមមើលខាងក្រោម។

[63] ដូចជើងទំព័រខាងលើ។

00526312



i. ទារុណកម្ម

៣៣. សេចក្តីពន្យល់អនុសញ្ញាទីក្រុងហ្សឺណែវ ដាក់ចេញនូវគន្លឹះចំនួនបី ដែលកំណត់ពីទារុណកម្ម។ ទីមួយ ចំណុចចាប់ផ្តើមរបស់អំពើមួយដើម្បីបង្កឲ្យមានទារុណកម្ម គឺសកម្មភាពនោះត្រូវតែពាក់ព័ន្ធនឹងការបង្កឲ្យមានការឈឺចាប់ លើសពីការប្រើកម្លាំងបាយទៅលើបុរណភាពផ្នែករាងកាយ ឬផ្នែកស្មារតី (moral integrity) របស់បុគ្គលនោះ។ ទីពីរ គឺគោលបំណងនៅពីក្រោយអំពើដែលកំណត់ថា តើអំពើនោះបង្កឲ្យមានទារុណកម្មឬយ៉ាងណាមិនមែនការឈឺចាប់ផ្ទាល់នោះទេ។ ហេតុដូច្នេះ ការឈឺចាប់ដែលបានកើតឡើងមកពីខាងក្នុង ឬ ដោយភាពចៃដន្យតែម្យ៉ាងដែលបណ្តាលមកពីការដាក់ទណ្ឌកម្មដែលធ្វើស្របច្បាប់មិនត្រូវបានរាប់បញ្ចូលទេ ។ ទីបី គោលបំណង គឺអាចគ្រាន់តែទទួលបានចម្លើយសារភាព ឬព័ត៌មានតែប៉ុណ្ណោះ។ ដូច្នេះ ប្រសិនជាបង្កការឈឺចាប់ ត្រូវបានប្រព្រឹត្តទៅលើបុគ្គលណាម្នាក់ ដោយមិនមានចេតនាចង់យកព័ត៌មាន ឬចម្លើយសារភាព ពីបុគ្គលម្នាក់ទេនោះ អំពើនោះមិនអាចបង្កើតជាទារុណកម្មបានទេ[64]។

៣៤. តុលាការ ICTY បានលើកឡើងថា សកម្មភាពណាមួយនៃទារុណកម្ម ត្រូវតែកើតឡើងដោយ "ចេតនា"[65]។ ដូច្នេះ លក្ខខណ្ឌតម្រូវកម្រិតខ្ពស់មួយ សម្រាប់ឲ្យមាន*ចេតនាឧក្រិដ្ឋ* ដែលចាំបាច់សម្រាប់ឧក្រិដ្ឋកម្ម គឺមានចែងស្រាប់ទៅហើយក្នុងតុលាការ ICTY។ ការព្រហើននឹងមិនគ្រប់គ្រាន់នោះទេ[66]។

៣៥. យ៉ាងណាក៏ដោយ អ.វ.ត.ក ត្រូវងាកចេញពីយុត្តិសាស្ត្រតុលាការ ICTY ក្នុងខណៈដែល អ.វ.ត.ក មិនមែនជាតំណាងនិយមន័យទារុណកម្មនៅក្នុងអនុសញ្ញាក្រុងហ្សឺណែវនោះ។ តុលាការ ICTY

---

64 សេចក្តីពន្យល់ អនុសញ្ញាក្រុងហ្សឺណែវទី IV, មាត្រា១៤៧ *អាចមើលបាននៅគេហទំព័រ៖* http://www.icrc.org/ihl.nsf/COM/380-600169?OpenDocument។

65 សាលដីកាតុលាការកំពូលក្នុងរឿងក្តី *Kunarac* កថាខណ្ឌ១៥៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Limaj និងអ្នកផ្សេងទៀត,* សំណុំរឿងលេខ IT-03-66-T, សាលដីកា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥, កថាខណ្ឌ ២៣៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Furundžija,* សំណុំរឿងលេខ IT-95-17/1-T, សាលក្រម ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨, កថាខណ្ឌ ១៦២។ សាលក្រម *Kunarac*, កថាខណ្ឌ ៤៩៧។

66 "ការបង្កឲ្យមានការឈឺចាប់ និងរងការឈឺចាប់ ដែលត្រូវបានលើកឡើងថា បង្កឲ្យកើតជាទារុណកម្ម ត្រូវតែមានចេតនា មានន័យថា អំពើនោះត្រូវតែបានធ្វើឡើយដោយគិតទុកជាមុន ដូច្នេះទារុណកម្មមិនអាចនឹងប្រព្រឹត្តឡើងដោយការធ្វេសប្រហែស ឬព្រហើននោះទេ" GUÉNAËL METTRAUX, INTERNATIONAL CRIMES AND THE AD HOC TRIBUNALS 116, (Oxford University Press 2005); M.E. Badar, *Drawing the Boundaries of Mens Rea in the Jurisprudence of the International Criminal Tribunal for the Former Yugoslavia*, 6 INT'L CRIM. LAW REV. (2006) 313, 321.

បានពង្រីកនិយមន័យទារុណកម្មថាៈ "ត្រូវមានអំពើសកម្ម ឬអកម្ម កើតឡើង ដើម្បីទទួលបាននូវចម្លើយសារភាព ឬព័ត៌មាន ឬដើម្បីដាក់ទោស គម្រាមកំហែង ឬបង្ខិតបង្ខំទៅលើជនរងគ្រោះ ឬតតិយជនឬរើសអើងទៅលើជនរងគ្រោះ ឬតតិយជន ទោះបីជាផ្អែកលើមូល ហេតុណាមួយក៏ដោយ"[67]។ និយមន័យទារុណកម្ម នៅតុលាការ ICTY "គឺមានចេតនាចង់ឆ្លុះបញ្ចាំងធាតុផ្សំសំខាន់ៗនៃបទឧក្រិដ្ឋ ដូចមានចែងក្នុង អនុសញ្ញាឆ្នាំ១៩៨៤ ប្រឆាំងនឹងទារុណកម្ម និងសកម្មភាពព្រៃផ្សៃ អមនុស្សធម៌ ឬការប្រមាថ និងទណ្ឌកម្មផ្សេងៗ [("CAT")]"..."[68] ប៉ុន្តែក្នុងអំឡុងពីឆ្នាំ១៩៧៥-៧៩ CAT មិនទាន់មាននោះទេ។ ដូច្នេះ CAT មិនអាចយកមកអនុវត្តនៅ អ.វ.ត.ក បានទេ ។ ក្នុងការប្រើនិយមន័យទារុណកម្ម ដោយផ្អែកលើធាតុផ្សំសំខាន់ៗនៃបទឧក្រិដ្ឋដូចមានចែងក្នុង CAT គឺជាការរំលោភបំពានទៅលើគោលការណ៍ *គ្មានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង*។

៣៦. និយមន័យទារុណកម្ម ដ៏ទូលំទូលាយ នៅតុលាការ ICTY រួមមាន ទារុណកម្ម គឺជាមធ្យោបាយក្នុងការដាក់ទោស បំភិតបំភ័យ បង្ខិតបង្ខំ ឬប្រកាន់បែងចែក ដែលសុទ្ធតែមិនមែនជានិយមន័យដែលមានក្នុងសេចក្តីពន្យល់អនុសញ្ញាក្រុងហ្សឺណែវឡើយ។ ច្បាប់បង្កើត អ.វ.ត.ក បានចែងយ៉ាងច្បាស់ថា ទារុណកម្មគឺផ្អែកលើអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ។ តាមលក្ខណៈតក្កវិជ្ជា និងជាពិសេសនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដូចជា ប្រទេសកម្ពុជា និយមន័យទារុណកម្ម ត្រូវតែដកស្រង់ចេញប្រភពដែលបានលើកឡើង។ នៅក្នុងករណីនេះ អនុសញ្ញាទីក្រុងហ្សឺណែវ គឺជាប្រភពដែលបានលើកឡើង ហើយបណ្តាធាតុផ្សំរបស់ទារុណកម្ម គឺមានកំណត់នៅក្នុងការសេចក្តីពន្យល់[69]។ ប្រសិនបើ អ.វ.ត.ក ចង់រកឱ្យឃើញថាខ្លួនមានយុត្តាធិការលើអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ រួមមាន ទារុណកម្ម ឬយ៉ាងណានោះ អ.វ.ត.ក ត្រូវអនុវត្តទៅតាមការកំណត់ដូចមានចែងក្នុងសេចក្តីពន្យល់ចំពោះអនុសញ្ញាទីក្រុងហ្សឺណែវ។

៣៧. ទារុណកម្មជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ មិនអាចរួមបញ្ចូល "ពិសោធន៍បែបជីវសាស្ត្រ"ទេ។ ពិសោធន៍បែបជីវសាស្ត្រ ត្រូវបានចុះជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរក្នុង

---

[67] សាលក្រមលើរឿងក្តី *Brđanin*, កថាខណ្ឌ ៤៨១(៣)។

[68] Ken Roberts, *The contribution of the ICTY to the Grave Breaches Regime*, 7(4) J. INT'L CRIM. JUST 743, 756 (2009); *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤៨១។

[69] បន្ថែមលើមាត្រា ៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលចែងថា "គ្មានបទឧក្រិដ្ឋអាចត្រូវដាក់ទណ្ឌកម្ម ដោយការអនុវត្តការដាក់ទណ្ឌកម្ម ដែលមិនមានចែងក្នុងច្បាប់ មុនពេលដែលបទឧក្រិដ្ឋនោះត្រូវបានប្រព្រឹត្តឡើងនោះទេ (បកប្រែក្រៅផ្លូវការ)។

អនុសញ្ញាក្រុងហ្សឺណែវ[70] ប៉ុន្តែមិនត្រូវបានរៀបរាប់នៅក្នុងបញ្ជីនៃអំពីបំពារបំពានយ៉ាងធ្ងន់ធ្ងរ ដែលអាចអនុវត្តបាននៅ អ.វ.ត.ក ទេ។ ការមិនរួមបញ្ចូល ពិសោធន៍បែបជីវសាស្ត្រនៅ អ.វ.ត.ក បង្ហាញឱ្យឃើញថា អ.វ.ត.ក គ្មានចេតនាចង់ឱ្យមានយុត្តាធិការជាពិសេស លើបទល្មើសរំលោភបំពានធ្ងន់ធ្ងរនេះទេ។ ក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដូចជា ប្រទេសកម្ពុជានេះ បទល្មើស ត្រូវតែកំណត់ឱ្យបានច្បាស់។ ការបកស្រាយមិនច្បាស់លាស់ រវាងអនុសញ្ញាក្រុងហ្សឺណែវ និងមាត្រា ៦ នៃច្បាប់បង្កើត អ.វ.ត.ក ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ការប្រព្រឹត្តដូចនេះ គឺគោរពទៅតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដូចមានចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ ទារុណកម្មមិនអាចរួមបញ្ចូលពិសោធន៍បែបជីវសាស្ត្របានទេ។

### ii. ការបំផ្លាញ និងធ្វើឱ្យ ខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិដោយមិនមានហេតុផលចាំបាច់ខាងយោធា និងដែលធ្វើឡើងដោយខុសច្បាប់និងដោយគ្មានត្រាប្រណី

៣៨. មាត្រា៦ នៃច្បាប់បង្កើត អ.វ.ត.ក ចែងថា៖ "បំផ្លាញ និងធ្វើឱ្យខូចខាតធ្ងន់ធ្ងរ ទៅលើទ្រព្យសម្បត្តិដោយមិនមានហេតុផលចាំបាច់ខាងយោធា និងដែលធ្វើឡើងដោយខុសច្បាប់ និងដោយគ្មានត្រាប្រណី"[71]។ នេះគឺជាភាពខុសប្លែកគ្នាពីអនុសញ្ញា ក្រុងហ្សឺណែវ និងមាត្រា២ នៃលក្ខន្តិកៈតុលាការ ICTY ដែលចែងថា៖ "ការបំផ្លិចបំផ្លាញ និងការរឹបអូសយកទ្រព្យសម្បត្តិយ៉ាងច្រើន"[72]។ ការមិនរួមបញ្ចូល ការរឹបអូសទ្រព្យសម្បត្តិនៅ អ.វ.ត.ក បង្ហាញថា អ.វ.ត.ក គ្មានចេតនាចង់មានយុត្តាធិការជាពិសេសលើបទល្មើសរំលោភបំពានធ្ងន់ធ្ងរនេះទេ។ ដូចបានលើកឡើងជាច្រើនដងរួចមកហើយថា នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដូចជា ប្រទេសកម្ពុជានេះ បទល្មើសត្រូវតែកំណត់ឱ្យបានច្បាស់។ ការបកស្រាយមិនច្បាស់លាស់ រវាងអនុសញ្ញាទីក្រុងហ្សឺណែវ និងមាត្រា ៦ នៃច្បាប់បង្កើត អ.វ.ត.ក ត្រូវតែដោះស្រាយដោយស្របទៅតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជា* ប្រយោជន៍ដល់ជនជាប់ចោទ។ ដូច្នេះ អ.វ.ត.ក មិន អាចមានយុត្តាធិការលើការរឹបអូសទ្រព្យសម្បត្តិឡើយ។

៣៩. អនុសញ្ញាក្រុងហ្សឺណែវ ចែងថា តម្រូវឱ្យមាន "អំពើបំផ្លិចបំផ្លាញយ៉ាងច្រើន"។ មាត្រា៦ នៃ

---

[70] អនុសញ្ញាទី I, មាត្រា ៥០; អនុសញ្ញាទី II, មាត្រា ៥១; អនុសញ្ញាទី III, មាត្រា ១៣០; អនុសញ្ញាទី IV, មាត្រា ១៤៧។

[71] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៦ (គូសបញ្ជាក់បន្ថែម)។

[72] អនុសញ្ញាទី I, មាត្រា ៥០; អនុសញ្ញាទី II, មាត្រា ៥១; អនុសញ្ញាទី III, មាត្រា ១៣០; អនុសញ្ញាទី IV, មាត្រា ១៤៧។

ច្បាប់បង្កើត អ.វ.ត.ក ក៏បានចែងយ៉ាងសាមញ្ញដែរថា តម្រូវឱ្យមាន "ការបំផ្លិចបំផ្លាញ"។ ដូច្នេះ ពាក់ព័ន្ធជាមួយបទល្មើសនេះមានលក្ខខណ្ឌតម្រូវពីរចំពោះការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។ ការបកស្រាយមិនច្បាស់លាស់ ត្រូវតែដោះស្រាយដោយស្របទៅតាមគោលការណ៍ *វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដោយត្រូវផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ។ ដូច្នេះ តម្រូវឱ្យមានការបំផ្លិចបំផ្លាញយ៉ាងច្រើនទៅលើទ្រព្យសម្បត្តិ។

៤០. ការខូចខាតធ្ងន់ធ្ងរ មិនអាចចាត់ទុកថាស្មើនឹងការបំផ្លិចបំផ្លាញយ៉ាងច្រើននោះទេ។ ការខូចខាតធ្ងន់ធ្ងរ[73] គឺជាលក្ខខណ្ឌតម្រូវកម្រិតទាប ក្នុងការបញ្ជាក់បើប្រៀបធៀបទៅនឹងការបំផ្លិចបំផ្លាញយ៉ាងច្រើន[74]។ ការខូចខាតធ្ងន់ធ្ងរ មិនមែនអំពើដែលមានចែងក្នុងច្បាប់ដែលអាចចាត់ទុកជាអំពើបំពារបំពាន យ៉ាងធ្ងន់ធ្ងរ នៅ អ.វ.ត.ក នោះទេ។ ការខូចខាតធ្ងន់ធ្ងរ មិនបានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ ជាអំពើជាមូលដ្ឋានមួយឡើយ[75]។ ក្នុងការចាត់ទុកថា ការខូចខាតធ្ងន់ធ្ងរ គឺអំពើជាដែលមានចែងក្នុងច្បាប់នោះ ជាការរំលោភបំពានទៅលើគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង*។

### iii. ការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង

៤១. សេចក្តីពន្យល់ចំពោះអនុសញ្ញាក្រុងហ្សឺណែវ ដាក់ចេញនូវលក្ខណៈសម្គាល់ចំនួនពីរ ចំពោះអំពើជាមូលដ្ឋាននៃការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង៖ ១) ចំណាប់ខ្មាំងត្រូវតែជា "បុគ្គលដែលត្រូវ

---

[73] "ការខូចខាត" ត្រូវបានពន្យល់ក្នុងវចនានុក្រមភាសាអង់គ្លេស Oxford ថា: "ការធ្វើ ឬបង្កឱ្យមានការខូចខាត; ធ្វើឱ្យឈឺ, ធ្វើឱ្យខូច, ធ្វើឱ្យរបួស; ឥឡូវនេះប្រើជាសាមញ្ញថាជាការធ្វើឱ្យរបួស(វត្ថុ) ដើម្បីបន្ថយ ឬបំផ្លាញតម្លៃរបស់វា"។ OXFORD ENGLISH DICTIONARY (ការបោះពុម្ពលើកទី២ ឆ្នាំ១៩៨៩), អាចមើលបាននៅគេហទំព័រ: http://dictionary.oed.com/cgi/entry/50057262?query_type=word&queryword=damage&first=1&max_to_show=10&sort_type=alpha&result_place=2&search_id=Dpfl-fti2Yu-18241&hilite=50057262 ។

[74] "ការបំផ្លិចបំផ្លាញ" មានពន្យល់ក្នុងវចនានុក្រមភាសាអង់គ្លេស Oxford ថា: "សកម្មភាពបំផ្លាញអគារ ឬវត្ថុធាតុសម្ព័ន្ធប្រភេទណាមួយ ដោយបំបែកជាចំណែក ឱ្យទៅជាកម្ទេចកម្ទី ឱ្យវិនាសអន្តរាយ អសារបង់ មិនអាចយកមកប្រើការបាន កម្ទេចឱ្យខ្ទេចឬសម្លាប់ដោយប្រើ ឬមិនប្រើសម្ភារៈ; ការបំផ្លាញ"។ OXFORD ENGLISH DICTIONARY (ការបោះពុម្ពលើកទី២ ឆ្នាំ១៩៨៩), *អាចមើលបាននៅគេហទំព័រ៖* http://dictionary.oed.com/cgi/entry/50062191?single=1&query_type=word&queryword=destruction&first=1&max_to_show=10។

[75] អ.វ.ត.ក អាចចោទប្រកាន់ជនជាប់ចោទចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវតែប៉ុណ្ណោះ។ *សូមមើល* កថាខណ្ឌ ៧-១០ *ដូចឯកសារយោងខាងលើ*។

គេដកហូតសេរីភាពដោយខុសច្បាប់" និង ២) ត្រូវមាន "ការគម្រាមកំហែងថានឹងពន្យា ពេលឃុំខ្លួនចំណាប់ខ្មាំង ឬសម្លាប់បុគ្គលនោះ" [76]។ ដោយយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានកំណត់ត្រឹមអនុសញ្ញាក្រុងហ្សឺណែវ នោះការរំលោភបំពានធ្ងន់ធ្ងរត្រូវតែកំណត់ដោយអនុលោមតាមអនុសញ្ញាក្រុងហ្សឺណែវ។ និយមន័យចំណាប់ខ្មាំងនៅតុលាការ ICTY ងាកចេញពីនិយមន័យក្នុងអនុសញ្ញាក្រុងហ្សឺណែវ។ អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY បានកែប្រែលក្ខណៈវិនិច្ឆ័យពី "ការពន្យាពេលឃុំខ្លួនចំណាប់ខ្មាំង ឬសម្លាប់បុគ្គលនោះ" ទៅជា "ការប្រព្រឹត្តអំពើដោយអមនុស្សធម៌ឬ ការស្លាប់" [77]។ ផលប៉ះពាល់នៃការផ្លាស់ប្តូរនេះ គឺដើម្បីបង្កើតនូវគម្លាតឱ្យកាន់តែទូលាយ ដែលអាចបំពេញលក្ខណៈវិនិច្ឆ័យនៃការចាប់ជាចំណាប់ខ្មាំងបាន។ និយមន័យដែលបានពង្រីកបន្ថែម មិនមែនជាច្បាប់ក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ទេ ហើយជនត្រូវចោទក៏មិនអាចប្រមើលទុក និងមិនអាចដឹងបានដែរ ក្នុងអំឡុងឆ្នាំ១៩៧៥-៧៩។ ដើម្បីអនុវត្តលក្ខណៈវិនិច្ឆ័យដែលទូលំទូលាយនៅតុលាការ ICTY ចំពោះ "ការប្រព្រឹត្តដោយអមនុស្សធម៌ ឬការស្លាប់" អាចនឹងបណ្តាលឱ្យមាន ការរំលោភបំពានគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង*។

៤២. គណៈកម្មាធិការពង្រាងច្បាប់លក្ខន្តិកៈរបស់ ICC បានយកជាសំអាងចំពោះធាតុផ្សំនៃការចាប់ជនស៊ីវិលជាចំណាប់ខ្មាំង ទៅលើអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការចាប់ជាចំណាប់ខ្មាំងនៅឆ្នាំ ១៩៧៩[78] មកធ្វើជាមូលដ្ឋាន។ ជាថ្មីម្តងទៀត ច្បាប់ដែលចេញមកពីអនុសញ្ញានេះមិនបានក្លាយជាច្បាប់នៅក្នុងឆ្នាំ ១៩៧៥-៧៩ ឡើយ ហើយក៏មិនអាចប្រមើលមើលឃើញជាមុន ហើយមិនអាចស្វែងរកបានដោយជនត្រូវចោទនៅក្នុងឆ្នាំ ១៩៧៥-៧៩ ឡើយ។

## IV. សំណូមពរ

**ដោយ**យោងសំអាងហេតុដូចមានជម្រាបបានជូនខាងលើ សហមេធាវីការពារក្តី សូមស្នើសុំដោយគោរពថាប្រសិនបើសហចៅក្រមស៊ើបអង្កេតរកឃើញថាអំពើបំពារបំពានធ្ងន់ធ្ងរអាចយកមកអនុវត្តនៅ អ.វ.ត.ក បាន(ទោះបីជាទឡ្ហីករណ៍របស់សហមេធាវីផ្ទុយពីនេះក្តី)សហចៅក្រមស៊ើបអង្កេតគួរតែ៖

ក. **កំណត់ព្រំដែន** ចំពោះអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរឱ្យនៅត្រឹមតែអ្វីដែលបានបញ្ជាក់ក្នុង

---

[76] សេចក្តីពន្យល់ពីអនុសញ្ញាទីក្រុងហ្សឺណែវទី IV, មាត្រា ១៤៧ អាចមើលបាននៅគេហទំព័រ: http://www.icrc.org/ihl.nsf/COM/380-600169?OpenDocument ។.

[77] សាលក្រមលើរឿងក្តី *Kordić*, កថាខណ្ឌ ៣១៤។

[78] DÖRMANN, ទំព័រ ១២៤។

អនុសញ្ញាទីក្រុងហ្សឺណែវ

ខ. **អនុវត្ត** អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ចំពោះតែស្ថានការណ៍ដែលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធអន្តរជាតិប៉ុណ្ណោះ

គ. **អនុវត្ត** អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរចំពោះតែករណី ដែលមានទំនាក់ទំនងរវាងអំពើជាមូលដ្ឋាន និង ជម្លោះប្រដាប់អាវុធអន្តរជាតិ

ឃ. **កំណត់ព្រំដែន** នៃនិយមន័យបុគ្គលដែលត្រូវការពារ ដោយផ្អែកលើសញ្ជាតិរបស់ពួកគេ ដូចមានកំណត់ក្នុងអនុសញ្ញាក្រុងហ្សឺណែវ និងមិនមែនដូចការកំណត់ក្នុងយុត្តិសាស្ត្រតុលាការ ICTY ដែលចេញផ្សាយកាលពីខែកក្កដា ឆ្នាំ១៩៩៩ ឡើយ

ង. **តម្រូវឲ្យ** *បំណងឧក្រិដ្ឋ* នៃបទល្មើសបំពារបំពានយ៉ាងធ្ងន់ធ្ងរ ត្រូវកើតឡើងដោយចេតនា ឬស្ថិតក្រោមកាលៈទេសៈជាក់លាក់ ជាការព្រហើន

ច. **កំណត់ព្រំដែន** ការអនុវត្តអំពើបំពារបំពានធ្ងន់ធ្ងរចំពោះបុគ្គលទាំងឡាយ ដែលបានប្រព្រឹត្ត ឬបានបញ្ជាឲ្យមានអំពើជាមូលដ្ឋាន

ឆ. **កំណត់ព្រំដែន** និយមន័យអំពើជាមូលដ្ឋាន ទៅតាមការកំណត់ដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ និងក្នុងសេចក្ដីពន្យល់អនុសញ្ញាទាំងនោះ។

សូមលោកសហចៅក្រមទទួលយកសំណើសុំនេះដោយក្ដីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០១០

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្ដម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**